# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jan-2012, 15:55
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១២

## <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការជំទាស់ទៅនឹងឯកសារ & សារណាបន្ថែមដោយអនុលោមតាមវិធាន ៩២

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Mojan SAMADI
Tomas HAMILTON

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

## ការជំទាស់ & សារណា

១. មេធាវីការពារក្តីរបស់លោក នួន ជា (ហៅថា "មេធាវីការពារក្តី") សូមដាក់ការជំទាស់ និង សារណាបន្ថែមទាក់ទងនឹងឯកសារ ដែលនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង 00២។ ដោយសារនេះជាបញ្ហាបឋម មេធាវីការពារក្តីសូមប្រកាន់ជំហរថា សារណានេះគួរតែត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ។ គ្រប់កាលៈទេសៈទាំង អស់មេធាវីការពារក្តីនឹងចាត់ទុកឯកសារនេះជាឯកសារសាធារណៈ។

## ក. ការជំទាស់របស់មេធាវីទៅនឹងការទទួលយកឯកសារផ្សេងៗ

២. មេធាវីការពារក្តីសូមលើកឡើងជាថ្មីម្តងទៀត ដោយយោងទៅនឹងការជំទាស់ជាទូទៅរបស់ខ្លួន ដែលបានដាក់ជូនរួចមកហើយ ទាក់ទិននឹងការទទួលយកឯកសារនៅក្នុងពេលសវនាការ[1]។

---

[1] សូមមើលឯកសារ E-9/26 "ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹង ឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ & សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី", ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, ERN 00665543–00665546។ ឯកសារ E-109/3 "ការកត់សម្គាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការ ដំណាក់កាលដំបូង", ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ERN 00717666–00717670។ ឯកសារ E-109/51 "ការឆ្លើយតប ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីការបស់ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យផ្តល់បញ្ជីភស្តុតាង និង វត្ថុតាងដែលពួកគេមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំ ជម្រះ", ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១, ERN 00725817–00725829 និងឯកសារ E-131/1/9 "ការជំទាស់ ការកត់ សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ERN 00752669–00752684។ កំណត់សំគាល់៖ មេធាវីការពារក្តីសូមគាំទ្របន្ថែមចំពោះការជំទាស់ ជាផ្នែកៗដែលដាក់ដោយក្រុមការពារក្តីដទៃទៀត ។ សូមមើលឯកសារ E-114 "ការជំទាស់របស់លោក អៀង សារី ទៅ នឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន" ថ្ងៃទី 0៦ ខែកញ្ញា ឆ្នាំ ២០១១, ERN 00728906–00728920។ ឯកសារ E-131/1/7 "ការជំទាស់របស់ក្រុមមេធាវីការពារក្តីអ្នកស្រី អៀង ធិរិទ្ធ ទៅនឹងបញ្ជីឯកសាររបស់ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសវនាការដំណាក់កាលដំបូង", ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ERN 00752656–00752665 និងឯកសារ E-131/6 "សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង", ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១១), ERN 00755162–00755173។

ដោយពិចារណាអំពីពេលវេលាកំណត់ដែលបានចេញដោយអង្គជំនុំជម្រះ[2] មេធាវីការពារក្ដី សូមគាំទ្រការជំទាស់ជាក់លាក់ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្ដីលោក អៀង សារី គឺ៖ (១) ឯកសារដែលដាក់ជូនដោយការិយាល័យសហព្រះរាជអាជ្ញា ("កសព")[3] និង (២) ឯកសារដែលមានក្នុងលេខជើងទំព័រនៃដីការដំណោះស្រាយ[4] នៅកថាខណ្ឌដែលកំពុងត្រូវបានអានក្នុងពេលសវនាការដែលទទួលស្គាល់ថា ត្រូវបានដាក់ជូនអង្គជំនុំជម្រះ[5]។

## ខ. ឯកសារដែលប្រើប្រាស់ដោយអង្គជំនុំជម្រះត្រូវតែបានធ្វើយថាភាព

៣. ដូចដែលបានដាក់ជូនរួចមកហើយ និងជាដដែលៗ មេធាវីការពារក្ដីនៅតែប្រកាន់ជំហរថា អង្គជំនុំជម្រះគួរតែទទួលស្គាល់តែឯកសារណាដែលត្រូវបានពិនិត្យពិច័យយ៉ាងមានប្រសិទ្ធិភាពលើយថាភាពរបស់វាដែលត្រូវបានស្នើឡើងដោយភាគី[6]។ ឯកសារដើមត្រូវតែបានស្នើសុំឲ្យបង្ហាញក្នុងតុលាការ។ លោក នួន ជា សូមរក្សាសិទ្ធិរបស់គាត់ក្នុងការតទល់ជាមួយនឹង យថា

[2] សូមមើលឯកសារ E-131/1 "អនុស្សរណៈអង្គជំនុំជម្មុំជម្រះសាលាដំបូងអំពី បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5" ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ERN 00747683–00747686។

[3] សូមមើលឯកសារ E-131/21 "ការជំទាស់របស់លោក អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួនរបស់ កសព សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង" ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១, , ERN 00761982–00762093 និងឯកសារ E-131/21.2 "ឧបសម្ព័ន្ធ", ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១, ERN 00760334–00760939។

[4] សូមមើលឯកសារ E-156 "ការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួនដែលមាននៅក្នុងជើងទំព័រក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលត្រូវបានអាននៅក្នុងសាលសវនាការ", ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១, ERN 00758892–00758894 និងឯកសារ E-156.2 "ឧបសម្ព័ន្ធ" ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១, ERN 00761982–00762093។

[5] សូមមើលឯកសារ E-141 អនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១",ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅទំព័រ[២-៣] និងឯកសារ E-1/16.1 ប្រតិចារិតថ្ងៃទី០៤, ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១, , ERN 00758703–00758789, នៅទំព័រ ៥៨-៥៩។

[6] សូមមើលជើងទំព័រលេខ១ ខាងលើ។

ភាពរបស់ឯកសារដែលប្រឆាំងនឹងរូបគាត់ ដែលត្រូវបានដាក់ដោយអង្គជំនុំជម្រះ កសព និង ភាគីផ្សេងទៀតនៅគ្រប់ពេលទាំងអស់ក្នុងអំឡុងពេលដំណើរការនីតិវិធី។ ដោយពិចារណា ឃើញថា ឯកសារដែលមានក្នុងដីការដំណោះស្រាយជាច្រើន និងឯកសារដែលត្រូវបានដាក់ ដោយ កសព ត្រូវបានផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូច្នេះមេធាវីការពារក្តីសូម លើកឡើងនូវសំណើរបស់ខ្លួនជាថ្មីម្តងទៀត សូមឲ្យកោះហៅលោក ឆាំង យុ នាយកមជ្ឈ មណ្ឌលឯកសារកម្ពុជាដើម្បីធ្វើជាសាក្សីក្នុងសំណុំរឿង ០០២ ឲ្យបានឆាប់បំផុត[7] គឺនៅក្នុង អំឡុងពេលដែលការពិភាក្សាលើការទទួលយកឯកសារ ដែលមិនទាន់បានកំណត់កាលបរិច្ឆេទ នៅឡើយនោះ[8]។

## គ. មេធាវីការពារក្តីនឹងដាក់ឯកសារដោយអនុលោមតាមច្បាប់ជាធរមានរបស់កម្ពុជា

៤. ដូចដែលបានជូនដំណឹងកាលពីលើកមុនរួចមកហើយ មេធាវីការពារក្តីមានបំណងដាក់ជូននៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងជាឯកសារដែលពាក់ព័ន្ធមានដូចជា:(i) ប្រធាន បទផ្សេងៗ ដែលត្រូវបានកំណត់នៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ជាច្រើនរបស់ មេធាវីការពារក្តី"[9], (ii) ដំណាក់កាលពីរដំបូងនៃការជម្លៀសប្រជាជន រួមបញ្ចូលទាំងសកម្ម ភាពល្មើសរបស់បុគ្គលជាក់លាក់មួយចំនួនដែលខកខានមិនបានបង្ហាញខ្លួននៅ ចំពោះមុខសហ

---

[7] សូមមើលឯកសារ E-93/4.3 "បញ្ជីឈ្មោះសង្ខេបសាក្សី-ក្រុមមេធាវីការពារក្តី នួន ជា", ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១, ERN 00707964–00708109 ។

[8] សូមមើលឯកសារ E-155 អនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង "ក្រុមសាក្សី និងអ្នក ជំនាញបន្ទាប់ដែលអង្គជំនុំជ្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១, ERN 00760310–00760311,ទំព័រទី២។

[9] សូមមើលឯកសារ E-9/26 "ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹង ឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី" ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១១, ERN 00665543–00665546, កថាខណ្ឌទី ៥ ។

ចៅក្រមស៊ើបអង្កេត អនុលោមតាមដីកាកោះហៅដែលមានសុពលភាព[10], (iii) ចំនួនមនុស្សស្លាប់ រួមទាំងបុគ្គលដែលអាចស្លាប់នៅពេលអនុវត្តផែនការដែលហៅថា ក-៥"[11] និង (iv) ការជ្រៀតជ្រែតខាងនយោបាយនៅ អវតក[12] ។

៥. អនុលោមតាមមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការដាក់ឯកសារបែបនេះអាចធ្វើឡើងនៅពេលណាមួយ "រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល"។ ដោយសារមេធាវីការពារក្តីមានបំណងដាក់ឯកសារមួយចំនួនរបស់ខ្លួនតាមរយៈTCE-38[13] បញ្ជីឯកសារលំអិតមួយនឹងដាក់នៅពេលខាងមុខ គឺនៅមុនការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ និងការពិភាក្សាលើឯកសារដែលយោងខាងលើ[14] ។

៦. លោក នួន ជា សូមរក្សាសិទ្ធិដាក់ឯកសារ និងភស្តុតាងទាំងអស់ ដើម្បីជាប្រយោជន៍ដល់ការបង្ហាញការពិតស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

សហមេធាវីការពារក្តីលោក **នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[10] សូមមើលឯកសារ E-131/1/9"ការជំទាស់ ការកត់ សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ERN 00752669–00752684, កថាខណ្ឌ ៣២។

[11] ដូចខាងលើ កថាខណ្ឌ ៣៣ ។

[12] ដូចខាងលើ កថាខណ្ឌ ៣៤ ។

[13] សូមមើលឯកសារ E-155អនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង "ក្រុមសាក្សី និងអ្នកជំនាញបន្ទាប់ដែលអង្គជំនុំជ្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១, ERN 00760310–00760311,ទំព័រទី២។ និងឯកសារ E-131/1.1 "ឧបសម្ព័ន្ធក សម្ងាត់៖ បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, ERN 00747687–00747694 ។

[14] សូមកត់សំគាល់ថាឯកសារភាគច្រើន ជាផ្នែកនៃសំណុំរឿងរួចហើយ ។